ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៥ លេខ ៤៣_៤៤ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

ក

មាតិកា

I ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៦.១១.៩៦ ព្រះរាជក្រឹត្យ នស/រកត/១១៩៦/៨០ តែងតាំងលោក អ៊ុង ប៊ុនហ៊ួរ ជាឧកញ៉ា ១៨៤៥

២៦.១១.៩៦ ព្រះរាជក្រឹត្យ នស/រកត/១១៩៦/៨១ តែងតាំងឯកឧត្តម ឧត្តមសេនីយ៍ ឯក ឈឹម និមយ៉ុន និងឯកឧត្តម ឧត្តមសេនីយ៍ឯក ជៀន ដែល ជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ ១៨៦

II ទីស្តីការគណៈរដ្ឋមន្ត្រី

១—អនុក្រឹត្យ

១៨.១១.៩៦ អនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពីរបបឧបត្ថម្ភចំពោះឃោធិន ពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ ១៨៤៧

២០.១១.៩៦ អនុក្រឹត្យលេខ ៨៧ អនក្រ.បក ស្តីពីប្រាក់បំណាច់និងប្រាក់ឧបត្ថម្ភ ផ្សេងៗ សំរាប់មន្ត្រីរាជការ បំពេញភារកិច្ចនៅប្រទេសក្រៅ ១៥៥

១៩.១១.៩៦ អនុក្រឹត្យលេខ ១៩៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៨៦១

១៩.១១.៩៦ អនុក្រឹត្យលេខ ១៩៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៨៦២

១៩.១១.៩៦ អនុក្រឹត្យលេខ ១៩៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៨៦៣

១៩.១១.៩៦ អនុក្រឹត្យលេខ ២០០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៨៦៤

១៩.១១.៩៦ អនុក្រឹត្យលេខ ២០១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៨៦៦

១៩.១១.៩៦ អនុក្រឹត្យលេខ ២០២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៨៦៧

២—សេចក្ដីសំរេច

១៨.១១.៩៦ សេចក្ដីសំរេចលេខ ៤៥ សសរ ស្ដីពីការបង្កើតគណៈកម្មការត្រួតពិនិត្យលក្ខណៈសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ១៨៦៨

២២.១១.៩៦ សេចក្ដីសំរេចលេខ ៤៦ សសរ ស្ដីពីការបង្កើតគណៈកម្មការអន្តរក្រសួងមួយធ្វើការវាយតំលៃលើការប៉ះពាល់ផលសំណង់ផ្ទះសំបែង និងដីធ្លីប្រជារាស្ត្រ ក្នុងគំរោងសាងសង់ស្ពានឆ្លងកាត់ទន្លេមេគង្គក្នុងខេត្តកំពង់ចាម ១៨៦៩

III ការងារបណ្ដាក្រសួង

១—ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

ប្រកាស

១៩.១១.៩៦ ប្រកាសលេខ ៦៥០ ផក.ប្រក អនុញ្ញាតអោយលោក យ៉ិវ ពៅ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៤០ សេះ ១៨៧១

១៩.១១.៩៦ ប្រកាសលេខ ៦៥១ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី កែវ អៀង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៧០ សេះ ១៨៧១

១៩.១១.៩៦ ប្រកាសលេខ ៦៥២ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ពុយ ស៊ូកន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឡផលិតឥដ្ឋ ក្បឿង ១៨៧២

១៩.១១.៩៦ ប្រកាសលេខ ៦៥៣ផក.ប្រក អនុញ្ញាតអោយលោក អ៊ុង ង៉ាក់សេង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឡផលិតឥដ្ឋ ក្បឿង ១៨៧២

១៩.១១.៩៦ ប្រកាសលេខ ៦៥៤ផក.ប្រក អនុញ្ញាតអោយលោក ចុង ឈីងលី ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការសិប្បកម្មផលិតការ៉េម និង ទឹកផ្លែឈើ ១៨៧៣

២—ទីស្តីការរដ្ឋមន្ត្រីក្រសួងព័ត៌មាន

ប្រកាស

២៨.១១.៩៦ ប្រកាសលេខ ៣០៧/៩៦ ពម.ប្រក អនុញ្ញាតផ្ទេរសិទ្ធិចាងហ្វាង និងឈ្មោះសារពិតមាន «សង្គមខ្មែរ» មក«សេរីភាពខ្មែរ » ដោយមានលោក សម សារិ ជាចាងហ្វាងការផ្សាយ ១៨៧៤

៣—ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

១៨.១១.៩៦ ប្រកាសលេខ ៩៥១ អយក.ប្រក ស្តីពីការអនុញ្ញាតអោយបើក សាលាមត្តេយ្យឯកជន ម៉ុន្តេសសូរី ១៨៧៥

៤—ទីស្តីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ប្រកាស

១៨.១១.៩៦ ប្រកាសលេខ ៧២ ប្រក.បល ៩៦ ស្តីពីការផ្ទេរមន្ត្រីរាជការ ១៨៧៧

១៨.១១.៩៦ ប្រកាសលេខ ៧៣ បល.៩៦ ស្តីពីការផ្ទេរមន្ត្រីរាជការ ១៨៧៩

១១.៩៦ ប្រកាសលេខ ៧៥ ប្រក.បល.៩៦ ស្តីពីការផ្ទេរមន្ត្រីរាជការ ១៨៨០

៥—ទីស្តីការក្រសួងធម្មការ និង សាសនា

សេចក្តីសំរេច

២០.១១.៩៦ សេចក្តីសំរេចលេខ ២៣១/៩៦ កធស អនុញ្ញាតច្បាប់ជាគោលការណ៍អោយបើកស្នាក់ការថ្នាក់បង្គំ នៃសាសនាម៉ឺលីក នៅទីរួម ខេត្តក្រចេះ ១៨៨១

២០.១១.៩៦	សេចក្ដីសំរេចលេខ ២៣៣/៩៦ កធស អនុញ្ញាតឲ្យបជាគោលការណ៍អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះត្រីនិកាយប្រូតេស្តង់ ឈ្មោះ « ព្រះវិហាររដ្ឋវចិរូត នៅខ័ណ្ឌទួលគោក រាជធានីភ្នំពេញ	១៨៨២
២០.១១.៩៦	សេចក្ដីសំរេចលេខ ២៣៤/៩៦ កធស អនុញ្ញាតឲ្យបជាគោលការណ៍អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះសាសនាគ្រីស្តឈ្មោះ «ក្រុមជំនុំ គ្រិស្តបរិស័ទខ្មែរបាប់ទីស្ទ » នៅស្រុកកញ្ជ្រៀច ខេត្តព្រៃវែង	១៨៨៤
២០.១១.៩៦	សេចក្ដីសំរេចលេខ ២៣៥/៩៦ កធស អនុញ្ញាតឲ្យបជាគោលការណ៍អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្តឈ្មោះ « ព្រះវិហារសាវ័កថ្មី » ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ	១៨៨៥
២០.១១.៩៦	សេចក្ដីសំរេចលេខ ២៣៧/៩៦ កធស អនុញ្ញាតឲ្យបជាគោលការណ៍អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្តនិកាយឈ្មោះ «ព្រះវិហារសេវេនដេយអាត់វេនទីស្ត » មួយកន្លែងនៅស្រុកសិរីសោភ័ណខេត្តបន្ទាយមានជ័យ	១៨៨៧

I - ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត/១១៩៦/៨០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក អ៊ុង ប៊ុនហ៊ុង

ជា

ឧកញ៉ា

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ព្រះហស្ថលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ នស/រកត/១១៩៦/៨១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង កម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំង ឯកឧត្តមឧត្តមសេនីយ៍ឯក **ឈឹម ឡិមយ៉ុន** និង ឯកឧត្តមឧត្តមសេនីយ៍ឯក **ជឿន ជែល** ជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ មានឋានៈស្មើរដ្ឋមន្ត្រីបន្ថែមលើភារកិច្ចរបស់ឯកឧត្តមឧត្តមសេនីយ៍ឯកទាំងពីរ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបាន សំរេចព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

II- ទីស្ដីការគណៈរដ្ឋមន្ត្រី

១—អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៤៦ អនក្រ.បក

ស្ដីពីរបបឧបត្ថម្ភចំពោះយោធិនពលី

មរណៈបន្តស្លាប់បាត់ខ្លួននិង ពិការ

* * * * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៦ ស្ដីពីការតែតាំងនាយករដ្ឋ ន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២ ន.ស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថៃទី ២៤ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៩០ ចុះថ្ងៃទី ៣១ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០៧ នស.៩៤ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ នស.រកត ០១៩៦.០៧ ចុះថ្ងៃទី ២៤ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងការពារជាតិ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង ដោយមានការយល់ព្រមពីគណៈរដ្ឋមន្ត្រីផង

សម្រេច

មាត្រា ១ : យោធិនទាំងពីរភេទដែលត្រូវទទួលស្គាល់ជាយោធិនពលី មរណៈ បង្កស្លាប់ និង បាត់ខ្លួនត្រូវមានលក្ខណៈសម្បត្តិដូចទៅ :

ក–យោធិនពលី គឺជាយោធិនដែលបានបាត់បង់ជីវិត នៅពេលដែលបាន ទទួលបញ្ជាទៅប្រយុទ្ធចូលរួមបំរើការប្រយុទ្ធ ហ្វឹកហាត់ជំនាញគ្រោះថ្នាក់បំផុត ធ្វើការពិសោធន៍ដ៏មានគ្រោះថ្នាក់និងដោយសារគ្រោះថ្នាក់ធម្មជាតិ ក្នុងតំបន់ គ្រោះថ្នាក់ ។

ខ–យោធិនមរណៈ គឺជាយោធិនដែលបានទទួលបញ្ជាទៅបំពេញការ ងារក្នុងតំបន់ធម្មតាហើយត្រូវទទួលគ្រោះថ្នាក់បាត់បង់ជីវិតដោយសារការងារទាំង នោះ ឬ ដោយសារជំងឺ ។

គ–យោធិនបង្កស្លាប់ គឺជាយោធិនដែលបានបាត់បង់ជីវិតដោយ ធ្វើអត្តឃាដ ឬដោយសារ បង្កគ្រោះថ្នាក់ដល់បាត់បង់ជីវិតដោយផ្ទាល់ ឬ ប្រយោល មកពីល្មើសច្បាប់វិន័យ និង បទបញ្ជា ។

ឃ–យោធិនដែលបាត់ខ្លួន គឺជាយោធិនដែលបានទទួលបញ្ជាអោយ ទៅប្រយុទ្ធចូលរួមបំរើ ប្រយុទ្ធហ្វឹកហាត់ជំនាញឯកទេស និងធ្វើការពិសោធន៍ប្រកប ដោយគ្រោះថ្នាក់ហើយត្រូវបាត់ខ្លួនដែលពុំអាចសន្និដ្ឋានបានថាស្លាប់ ឬ រស់ រត់ចោលជួរ រត់ចូលខ្មាំង ឬ ត្រូវខ្មាំងចាប់ ។

មាត្រា ២ : យោធិនទាំងពីរភេទ ដែលត្រូវទទួលស្គាល់ជាយោធិនពិការ ត្រូវមានលក្ខណៈ សម្បត្តិដូចតទៅ :

ពិការដោយសារបាត់បង់សរីរាង្គណាមួយ ឬច្រើននៅលើរាងកាយហើយត្រូវ ចែកចេញជាពីរ ប្រភេទគឺ ប្រភេទ «ក» និងប្រភេទ«ខ» ។

យោធិនពិការប្រភេទ«ក» គឺជាយោធិនមានជំងឺរបួស មិនបណ្តាលអោយ បាត់បង់ជីវិត តែ ក្លាយជាយោធិនពិការ ដោយចូលរួមបំរើប្រយុទ្ធ ហ្វឹកហាត់ជំនាញ គ្រោះថ្នាក់ធ្វើការពីសោធន៍ មានគ្រោះថ្នាក់ និងដោយសារគ្រោះថ្នាក់ធម្មជាតិក្នុង តំបន់គ្រោះថ្នាក់ ត្រូវបានចែកចេញជា ៤ កំរិតថ្នាក់ :

–កំរិតថ្នាក់ ១ មានកំរិតបាត់បង់សមត្ថភាពការងារលើសពី ៨០ ភាគរយ

–កំរិតថ្នាក់ ២ មានកំរិតបាត់បង់សមត្ថភាពការងារលើសពី ៦០ ភាគរយ

–ការិតថ្នាក់ ៣ មានការិតបាត់បង់សមត្ថភាពការងារលើសពី ៤០ ភាគរយ
–ការិតថ្នាក់ ៤ មានការិតបាត់បង់សមត្ថភាពការងារលើសពី ២០ ភាគរយ

យោធិនពិការប្រភេទ «ក »ស្លាប់ដោយសាររបួសស្មើរើដែលមានលិខិតបញ្ជាក់ពីមន្ទីរពេទ្យរដ្ឋត្រូវបានទទួលស្គាល់ជាយោធិនពលី ។

យោធិនពិការប្រភេទ«ក »ត្រូវទទួលរបួសបន្ថែមទៀតដោយសារចូលរួមប្រយុទ្ធ ប្រយុទ្ធផ្ទាល់ ឬបំពេញការងារធម្មតា ត្រូវបានពិនិត្យវាយតំលៃការិតថ្នាក់ឡើងវិញ ។

យោធិនពិការប្រភេទ«ខ » គឺជាយោធិនដែលមានជំងឺរបួសមិនបណ្តាលអោយបាត់បង់ជីវិតតែក្លាយទៅយោធិនពិការ ដោយទទួលបញ្ជាទៅបំពេញការងារក្នុងតំបន់ធម្មតាហើយត្រូវទទួលគ្រោះថ្នាក់ ត្រូវបានចែកចេញ ៣ ការិតថ្នាក់ :
–ការិតថ្នាក់ ១ មានការិតបាត់បង់សមត្ថភាពការងារលើសពី ៨០ ភាគរយ
–ការិតថ្នាក់ ២ មានការិតបាត់បង់សមត្ថភាពការងារលើសពី ៦០ ភាគរយ
–ការិតថ្នាក់ ៣ មានការិតបាត់បង់សមត្ថភាពការងារលើសពី ៤០ ភាគរយ

យោធិនពិការប្រភេទ«ខ »ស្លាប់ដោយសារជម្ងឺស្មើរើដែលមានលិខិតបញ្ជាក់ពីមន្ទីរពេទ្យរដ្ឋ ត្រូវបានទទួលស្គាល់ជាយោធិនមរណៈ ។

យោធិនពិការប្រភេទ «ខ » ត្រូវរបួសបន្ថែមទៀតដោយសារចូលរួមប្រយុទ្ធ ឬប្រយុទ្ធផ្ទាល់ត្រូវកំណត់ទទួលស្គាល់ជាយោធិនពិការប្រភេទ «ក » វិញ ។

មាត្រា ៣ : ការវាយតម្លៃប្រភេទថ្នាក់ពិការ គឺត្រូវធ្វើឡើងដោយក្រុមប្រឹក្សាវាយតម្លៃមួយរបស់ក្រសួងការពារជាតិដោយផ្អែកតាមសេចក្តីប្រកាសអន្តរក្រសួងដែលមានសមាសភាព :
–ក្រសួងការពារជាតិ
–ក្រសួងសុខាភិបាល
–ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន

មាត្រា ៤ :យោធិនទាំងពីរភេទ ដែលមានចែងក្នុងមាត្រា១ ត្រូវបានទទួលប្រាក់ឧបត្ថម្ភដូចតទៅ :

ក—យោធិនពលី

–ឧបត្ថម្ភថវិកា ស្មើនឹងទឹកប្រាក់ ៩ខែ នៃប្រាក់បៀវត្ស សរុបចុងក្រោយរបស់យោធិនពលីជូនដល់គ្រួសារសព ឬ កងឯកភាពដែលទទួលបន្ទុករៀបចំធ្វើបុណ្យបូជា ឬ បញ្ចុះសព។

–ឧបត្ថម្ភថវិកាមួយលើកដំបូង ជូនគ្រួសារសព ស្មើនឹងទឹកប្រាក់ចំនួន ១៥ ខែនៃប្រាក់បៀវត្ស សរុបចុងក្រោយ របស់យោធិនពលី ។

–ឧបត្ថម្ភថវិកាជំនួយគ្រួសារ ជាប្រចាំខែ ជូនដល់ប្រពន្ធ ឬ ប្តី កូនបង្កើត ឬ ឪពុកម្តាយបង្កើតរបស់យោធិនពលី តាមសេចក្តីកំណត់របស់រាជរដ្ឋាភិបាល ។

ខ—យោធិនមរណៈ

–ឧបត្ថម្ភថវិកា ស្មើនឹងទឹកប្រាក់ចំនួន ៧ ខែ នៃប្រាក់បៀវត្ស សរុបចុងក្រោយរបស់យោធិនមរណៈជូនដល់គ្រួសារសព ឬ កងឯភាពដែលទទួលបន្ទុករៀបចំធ្វើបុណ្យបូជា ឬ បញ្ចុះសព ។

–ឧបត្ថម្ភថវិកាមួយលើកដំបូង ជូនគ្រួសារសព ស្មើនឹងទឹកប្រាក់ចំនួន ១២ ខែនៃប្រាក់បៀវត្សសរុបចុងក្រោយ របស់យោធិនមរណៈ ។

–ឧបត្ថម្ភថវិកាជំនួយគ្រួសារ ជូនដល់ប្រពន្ធ ឬ ប្តី កូនបង្កើត ឬ ឪពុកម្តាយបង្កើតរបស់យោធិនមរណៈ តាមសេចក្តីកំណត់របស់រាជរដ្ឋាភិបាល

គ—យោធិនបង្កស្លាប់

–ឧបត្ថម្ភថវិកា ស្មើនឹងទឹកប្រាក់ចំនួន ៥ ខែនៃប្រាក់បៀវត្ស សរុបចុងក្រោយរបស់យោធិនបង្កស្លាប់ ជូនដល់គ្រួសារសព ឬ កងឯកភាព ដែលទទួលបន្ទុករៀបចំធ្វើបុណ្យបូជា ឬ បញ្ចុះ សព ។

–ឧបត្ថម្ភថវិកាមួយលើកផ្តាច់ ជូនដល់គ្រួសារសពស្មើនឹងទឹកប្រាក់ចំនួន ១២ ខែនៃប្រាក់ បៀវត្ស សរុបចុងក្រោយរបស់យោធិនបង្កស្លាប់ ។

ឃ—យោធិនបាត់ខ្លួន :

–ឧបត្ថម្ភថវិកាជូនគ្រួសារ ស្មើនឹងទឹកប្រាក់បៀវត្ស សរុបចុងក្រោយរបស់យោធិនបាត់ខ្លួន ដោយគិតទាំងរបបអង្ករប្រចាំខែចាប់ពីខែ ឆ្នាំ បាត់ខ្លួនរហូតដល់គម្រប់ ១២ ខែ ។

-ចាប់ពីខែ ឆ្នាំ គម្រប់ ១២ ខែ គិតពីខែ ឆ្នាំ បាត់ខ្លួនមក គ្រួសារត្រូវបានទទួលប្រាក់ឧបត្ថម្ភ ដូចជាយោធិនពលី លើកលែងតែប្រាក់ឧបត្ថម្ភសំរាប់បូជា ឬ បញ្ចុះសពចេញ ។

-ក្នុងកំឡុងពេលកំពុងទទួលរបបឧបត្ថម្ភណាមួយ ក្នុងចំនុចទាំងពីរខាងលើយោធិនបាត់ខ្លួនបានវិលត្រឡប់មកកងឯកភាពដើម ឬ វិលទៅមូលដ្ឋានវិញការផ្តល់របបឧបត្ថម្ភត្រូវតែបញ្ឈប់ចាប់ពីខែ ឆ្នាំ ដែលយោធិនបាត់ខ្លួននោះមានមុខ ។

មាត្រា ៥ : ជនដែលមានគ្រប់លក្ខណៈសម្បត្តិ ទទួលរបបឧបត្ថម្ភ ពីយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួនគឺ :

-ឪពុក និងម្តាយបង្កើត ឬ អាណាព្យាបាលតាំងពីវ័យកុមាររបស់យោធិន បើសិនយោធិននោះនៅលីវ ។

-ប្រពន្ធ ឬ ប្តី របស់យោធិនមានលិខិតអាពាហ៍ពិពាហ៍ ហើយពុំទាន់រៀបចំអាពាហ៍ពិពាហ៍ជាថ្មីទៀត ។

-កូនបង្កើតរបស់យោធិនមានសំបុត្រកំណើតអាយុ ១៨ ឆ្នាំចុះ និង មានអាយុ ១៨ ឆ្នាំឡើងត្រូវមានលិខិតបញ្ជាក់កំពុងបន្តការសិក្សា ហើយពុំទាន់ទទួលនូវអាហារូបករណ៍ ឬ មានលិខិតបញ្ជាក់ពិការភាព ។

-ឪពុកម្តាយបង្កើត ឬ អាណាព្យាបាល ដែលមានកូនពលី ឬ មរណៈ ចំនួន មួយ ឬពីរឡើងទៅគឺត្រូវបានរបបឧបត្ថម្ភ គុណតាមចំនួនកូនដែលបានពលី ឬ មរណៈនោះ ។

មាត្រា ៦ : យោធិនទាំងពីរភេទ ដូចមានចែងក្នុងមាត្រ ២ ត្រូវបានទទួលរបបឧបត្ថម្ភដូចតទៅ

ក—ចំពោះយោធិនពិការប្រភេទ «ក» គ្រប់កំរិតថ្នាក់ :

១—ក្រោយពេលព្យាបាលជំងឺរបួស ជាសះស្បើយ និង មានលំនឹង ត្រូវបានទទួលរបបឧបត្ថម្ភបំប៉នសុខភាព នៅមជ្ឈមណ្ឌលបំប៉នសុខភាពតាមរយៈពេលកំណត់និងតាមកំរិតថ្នាក់ពិការគឺ :

-កំរិតថ្នាក់ ១ បានអនុញ្ញាតអោយសំរាកបំប៉នសុខភាពចំនួន ៩០ ថ្ងៃ

-កំរិតថ្នាក់ ២ បានអនុញ្ញាតអោយសំរាកបំប៉នសុខភាពចំនួន ៦០ ថ្ងៃ

-កំរិតថ្នាក់ ៣ បានអនុញ្ញាតអោយសំរាកបំប៉នសុខភាពចំនួន ៤៥ ថ្ងៃ

–កំរិតថ្នាក់ ៤ បានអនុញ្ញាតអោយសំរាកបំប៉នសុខភាពចំនួន ៣០ ថ្ងៃ

២–យោធិនពិការ ប្រសិនបើនៅបន្តការងារក្នុងកងយោធពលខេមរភូមិន្ទ បានទទួលរបបឧបត្ថម្ភជំនួយមុខរបួសបន្ថែមជាប្រចាំខែ ដោយគិតជាសមាមាត្រភាគរយនៃបៀវត្ស សរុបប្រចាំខែផ្ទាល់ខ្លួននិងតាមកំរិតថ្នាក់ពិការគឺបន្ថែមលើប្រាក់បៀវត្សប្រចាំខែផ្ទាល់ ខ្លួន ។

–កំរិថ្នាក់ ១ បានទទួលរបបឧបត្ថម្ភជាទឹកប្រាក់ចំនួនស្មើនឹង ៤៥ ភាគរយនៃប្រាក់បៀវត្សផ្ទាល់ ខ្លួនចុងក្រោយរបស់យោធិនពិការនោះ ។

–កំរិតថ្នាក់ ២ បានទទួលរបបឧបត្ថម្ភជាទឹកប្រាក់ចំនួនស្មើនឹង ៤០ ភាគរយនៃប្រាក់បៀវត្ស ផ្ទាល់ខ្លួនចុងក្រោយរបស់យោធិនពិការនេះ ។

–កំរិតថ្នាក់ ៣ បានទទួលរបបឧបត្ថម្ភជាទឹកប្រាក់ចំនួនស្មើនឹង ៣៥ ភាគរយនៃប្រាក់បៀវត្ស ផ្ទាល់ខ្លួន ចុងក្រោយរបស់យោធិនពិការនោះ ។

–កំរិតថ្នាក់ ៤ បានទទួលរបបឧបត្ថម្ភជាទឹកប្រាក់ចំនួនស្មើនឹង ៣០ ភាគរយៈនៃប្រាក់បៀវត្ស ផ្ទាល់ខ្លួនចុងក្រោយរបស់យោធិនពិការនោះ ។

៣–យោធិនពិការ ដែលក្រសួងការពារជាតិសំរេចអោយចេញពីជួរ កងយោធពលខេមរភូមិន្ទត្រូវបានទទួលរបបឧបត្ថម្ភប្រាក់អតីតភាពបំរើការងារមិនលើសពី ១២ខែដោយគិតរយៈពល បំរើកងយោធពលខេមរភូមិន្ទ ក្នុង១ឆ្នាំ ត្រូវបានទទួលប្រាក់ឧបត្ថម្ភអតីតភាពចំនួន ១ ខែ ។ ចំពោះយោធិនពិកាដែលបំរើកងទ័ពមិនទាន់គ្រប់រយៈពេល ១ឆ្នាំ ហើយត្រូវពិការ ក៏ត្រូវទទួល ប្រាក់អតីតភាព ចំនួន ១ ខែដែរ ។

៤–យោធិនពិការ ត្រូវបានទទួលរបបឧបត្ថម្ភមួយលើកដំបូង ស្មើនឹងទឹកប្រាក់ចំនួន

–កំរិតថ្នាក់១ ទទួលទឹកប្រាក់សរុបចំនួន ០៦ខែនៃប្រាក់បៀវត្ស សរុបចុងក្រោយរបស់យោធិនពិការនោះ ។

–កំរិតថ្នាក់២ ទទួលទឹកប្រាក់សរុបចំនួន ០៥ខែនៃប្រាក់បៀវត្ស សរុបចុងក្រោយរបស់យោធិនពិការនោះ ។

–កំរិតថ្នាក់៣ ទទួលទឹកប្រាក់សរុបចំនួន ០៤ខែនៃប្រាក់បៀវត្ស សរុបចុងក្រោយរបស់យោធិនពិការនោះ ។

–កំរិតថ្នាក់៤ ទទួលទឹកប្រាក់សរុបចំនួន ០៣ខែនៃប្រាក់បៀវត្ស សរុបចុងក្រោយរបស់យោធិពិការនោះ ។

៥–បានបន្តទទួលបើកប្រាក់បៀវត្សសរុបប្រចាំខែ ហើយបៀវត្ស សរុបនោះត្រូវគិតតាម ឋានន្តរសក្តិចុងក្រោយមុនពេលសំរេចអោយចេញពីជួរកងយោធពលខេមរភូមិន្ទ និងចំនួន កូននៅក្នុងបន្ទុកជាក់ស្តែងរបស់យោធិនពិការ ។

៦–យោធិនពិការដែលរស់នៅក្នុងមណ្ឌល យោធិនដែលចេញពីជួរកងយោធពលខេមរភូមិនត្រូវបានទទួលបន្ថែមនូវប្រាក់ឧបត្ថម្ភជំនួយមុខរបួសជារៀងរាល់ខែដោយគិតជា សមាមាត្រលើប្រាក់បៀវត្សសរុបផ្ទាល់ខ្លួនប្រចាំខែដូចខាងក្រោយ

–កំរិតថ្នាក់ ១ ទទួលបានប្រាក់ឧបត្ថម្ភមុខរបួសស្មើ ១០០ ភាគរយ

–កំរិតថ្នាក់ ២ ទទួលបានប្រាក់ឧបត្ថម្ភមុខរបួសស្មើ ៨០ ភាគរយ

–កំរិតថ្នាក់ ៣ ទទួលបានប្រាក់ឧបត្ថម្ភមុខរបួសស្មើ ៦០ ភាគរយ

–កំរិតថ្នាក់ ៤ ទទួលបានប្រាក់ឧបត្ថម្ភមុខរបួសស្មើ ៤០ ភាគរយ

៧–យោធិនពិការកំរិតថ្នាក់១ បានទទួលរបបឧបត្ថម្ភអ្នកបំរើផ្ទាល់ខ្លួនមួយនាក់ ហើយអ្នកបំរើ នោះត្រូវបានទទួលជាប្រចាំខែ រហូតដល់យោធិននោះស្លាប់ ស្មើនឹងបៀវត្សអប្បបរមាផ្ទាល់ ខ្លួនរបស់យោធិនមានឋានន្តរសក្តិជាពលទោ ។

ខ–យោធិនពិការប្រភេទ «ខ» គ្រប់កំរិតថ្នាក់ :

១–យោធិនពិការប្រភេទ«ខ»ដែលក្រសួងការពារជាតិសំរេចចេញពីជួរកងយោធពលខេមរភូមិន្ទនឹងបានទទួលប្រាក់ឧបត្ថម្ភអតីតភាពបំរើការងារមិនលើសពី ៨ ខែដោយគិតរយៈពេល បំរើកងយោធពលខេមរភូមិន្ទ ដូចក្នុងចំនួន កពា ខាងលើ ។

២–យោធិនពិការ ត្រូវបានទទួលរបបឧបត្ថម្ភតាមកំរិតថ្នាក់ពិការជាប្រចាំតាមកំរិតសមាមាត្រ ភាគរយនៃប្រាក់បៀវត្សផ្ទាល់ខ្លួនចុងក្រោយរបស់យោធិនពិការ :

–កំរិតថ្នាក់ ១ បានទទួលទឹកប្រាក់សរុបស្មើនឹង ៩០ភាគរយនៃបៀវត្ស ផ្ទាល់ខ្លួនចុងក្រោយរបស់យោធិន ។

–កំរិតថ្នាក់ ២ បានទទួលទឹកប្រាក់សរុបស្មើនឹង ៨០ភាគរយនៃបៀវត្ស ផ្ទាល់ខ្លួនចុងក្រោយរបស់យោធិន ។

–កំរិតថ្នាក់ ៣ បានទទួលទឹកប្រាក់សរុបស្មើនឹង ៧០ភាគរយនៃបៀវត្ស ផ្ទាល់ខ្លួនចុងក្រោយរបស់យោធិន ។

–ត្រូវបានទទួលឧបត្ថម្ភចិញ្ចឹមប្រពន្ធ ឬ ប្តី កូន ដូចយោធិនពិការប្រភេទ «ក» ។

គ–យោធិនពិការប្រភេទ «ក »និង«ខ »

គ្រប់កំរិតថ្នាក់ត្រូវបានទទួលរបបឧបត្ថម្ភបន្ថែម :

១–នារាល់ថ្ងៃបុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ និងថ្ងៃបុណ្យខួបរំលឹកគុណយោធិនពលី ពិការ (កំណត់ថ្ងៃបុណ្យភ្ជុំបិណ្ឌ)ត្រូវបានទទួលរបបឧបត្ថម្ភ ស្មើនឹងទឹកប្រាក់ឧបត្ថម្ភស្មើនឹងទឹកប្រាក់ឧបត្ថម្ភថ្ងៃបុណ្យរបស់មន្ត្រីរាជការកំពុងធ្វើការងារ

២–ពេលមានជម្ងឺ របួស ឬ ពេលរបួសសើរើ ត្រូវបានទទួលសង្គ្រោះព្យាបាលលុះជាសះស្បើយនៅតាមមន្ទីរពេទ្យរដ្ឋ ដោយឥតគិតថ្លៃ ។

៣–ត្រូវបានទទួលស្តារលទ្ធភាពពលកម្ម និងជួយបណ្តុះបណ្តាលមុខវិជ្ជាជីវៈនៅតាមមជ្ឈមណ្ឌលរបស់រដ្ឋដោយឥតគិតថ្លៃ និងបានហក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជនជួយ ចាត់ចែងដោះស្រាយការងារនិងមុខរបរតាមលទ្ធភាពនិងសមត្ថភាពរបស់យោធិនពិការ ។

៤– ចំពោះយោធនារីពិការ ត្រូវទទួលឧបត្ថម្ភបន្ថែមនូវការធានារ៉ាប់រងសង្គម ដូចជាស្ត្រីដែលកំពុងបំរើការងាររាជការដែរ ។

៥–យោធិនពិការដែលនៅបំរើការងារ ពេលគ្រប់លក្ខណៈសម្បត្តិចូលនិវត្តន៍គឺត្រូវប្តូរមកទទួលរបបសោធននិវត្តន៍វិញ ។

មាត្រា ៧ : រាល់ការចំណាយលើរបបឧបត្ថម្ភ ដូចជាបានចែងក្នុងមាត្រា ៤ និង ៦ត្រូវទទួលបន្ទុកដោយថវិការដ្ឋ ។ ក្រសួងការពារជាតិ ជាអ្នកទទួលបន្ទុកដោះស្រាយដូចខាងក្រោម ÷

–ការចំណាយសំរាប់បូជា ឬ បញ្ចុះសព ។

–ការចំណាយសំរាប់ឧបត្ថម្ភ ជូនគ្រួសារយោធិនពលី មរណៈបង្គស្លាប់ មួយលើកដំបូង ។

–ការចំណាយសំរាប់ឧបត្ថម្ភបំប៉នសុខភាពយោធិនពិការ ។

–ការចំណាយសំរាប់ឧបត្ថម្ភ ប្រាក់អតីតភាពការងាររបស់យោធិនពិការ មុនពេលសំរេចចេញពីជួរកងយោធពលខេមរភូមិន្ទ ។

–ការចំណាយសំរាប់ឧបត្ថម្ភជំយមុខរបួស របស់យោធិនពិការនៅបន្តការងារក្នុងកងយោធពលខេមរភូមិន្ទ ។

–ការដោះស្រាយប្រាក់បៀវត្សសរុប ៣ ខែ មុនពេលផ្ទេរយោធិនពិការទៅក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន ក្នុងរយៈពេលរង់ចាំក្រសួងសង្គមកិច្ចការងារ

និងអតីតយុទ្ធជនបំពេញសំណុំលិខិតបន្តដោះស្រាយប្រាក់ឧបត្ថម្ភ ។

ក្រៅពីរបបឧបត្ថម្ភ ដែលក្រសួងការពារជាតិទទួលបន្ទុកដោះស្រាយគឺក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជនជាអ្នកទទួលបន្ទុកដោះស្រាយបន្ត ។

មាត្រា ៨ : សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួង សង្គមកិច្ចការងារ និងអតីតយុទ្ធជន និងស្ថាប័ន ឬ ក្រសួងពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្ត តាមអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខានិងចុះហត្ថលេខាតទៅ ។

មាត្រា ៩ : បទញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

ភ្នំពេញ,ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៤៧ អនក្រ.បក

ស្តីពីប្រាក់បំណាច់និងប្រាក់ឧបត្ថម្ភផ្សេងៗ

សំរាប់មន្ត្រីរាជការបំពេញភារកិច្ចនៅក្រៅប្រទេស

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការ រៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

បានឃើញព្រះរាជក្រមលេខ ០៦ នស. ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និងលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១-៩៦/១០ ចុះថ្ងៃទី ២៤-០១-៩៦ ស្តីពីការ បង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការ រៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- ហើយមានការយល់ព្រមពីគណៈរដ្ឋមន្ត្រីផង

សំរេច

មាត្រា ១ . មន្ត្រីរាជការការទូត កុងស៊ុល និងមន្ត្រីរាជការស៊ីវិល និងយោធានៃព្រះរាជាណាចក្រកម្ពុជាដែលចាត់តាំងដាក់អោយទៅបំរើការ ឬបំពេញមុខងារ និងភារកិច្ចនៅក្រៅប្រទេសត្រូវមានសិទ្ធិទទួលនូវប្រាក់បំណាច់ ។

មាត្រា ២ : បណ្តាប្រទេស ក្រុង ដែលមានស្ថានទូត ស្ថានកុងស៊ុល ឬស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជាតាំងនៅ ត្រូវបែងចែកជា ៣ ប្រភេទ ក-ខ-គ ដូចតទៅនេះ ÷

ល.រ	ក	ខ	គ
១	សាធារណរដ្ឋបារាំង	១- សាធារណរដ្ឋប្រជាមានិតចិន	១-សាធារណរដ្ឋសង្គមនិយមវៀតណាម
	- ស្ថានឯកអគ្គរាជទូតប៉ារីស	- ស្ថានឯកអគ្គរាជទូតប៉េកាំង	- ស្ថានឯកអគ្គរាជទូតហាណូយ
	- គណបេសកកម្មអចិន្ត្រៃយ៍ប្រចាំអ៊ុយណេស្កូ-ប៉ារីស	២- សាធារណរដ្ឋឥណ្ឌា -ស្ថានឯកអគ្គរាជទូតញូដេលី	- ស្ថានឯកអគ្គកុងស៊ុលហូជីមិញ
២	ព្រះរាជាណាចក្រជប៉ុន	៣-សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ	២- សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
	- ស្ថានឯកអគ្គរាជទូត តូក្យូ	-ស្ថានឯកអគ្គរាជទូតព្យុងយ៉ាង	- ស្ថានឯកអគ្គរាជទូត

៣ សហរដ្ឋអាមេរិក

– ស្ថានឯកអគ្គរាជទូត វ៉ាស៊ីនតោន

– ស្ថានបេសកកម្មអចិន្ត្រៃយ៍ អម អ.ស.ប ញូយ៉ក

– ស្ថានឯកអគ្គកុងស៊ុល ឡូសអង់ហ្សិលេស

៥ ចក្រភពអង់គ្លេស

– ស្ថានឯកអគ្គរាជទូត ឡុងដ៍

៦ ប្រទេសអូស្ត្រាលី

– ស្ថានឯកអគ្គរាជទូត កំបែរ៉ា

៧ ប្រទេសកាណាដា

– ស្ថានឯកអគ្គរាជទូត អុតាវ៉ា

៨ ព្រះរាជាណាចក្របែលហ្ស៊ិក

– ស្ថានឯកអគ្គរាជទូត ប្រ៊ុចសែល

– ស្ថានបេសកកម្មអចិន្ត្រៃយ៍ អមសហគមន៍អឺរ៉ុប ប្រ៊ុចសែល

៩ ប្រទេសស្វីស

– ស្ថានបេសកកម្មអចិន្ត្រៃយ៍ ប្រចាំការិយាល័យ អ.ស.ប ហ្សឺណែវ

៤_ សាធារណរដ្ឋសហព័ន្ធរុស្ស៊ី

– ស្ថានឯកអគ្គរាជទូត ម៉ូស្គូ

៥_ ព្រះរាជាណាចក្រថៃ

– ស្ថានឯកអគ្គរាជទូតបាងកក

៦_ សាធារណរដ្ឋអារ៉ាប់អេស៊ីប

៨_ សាធារណរដ្ឋឥណ្ឌូណេស៊ី

– ស្ថានឯកអគ្គរាជទូត ហ្សាការតា

៩_ ប្រទេសម៉ាឡេស៊ី

– ស្ថានឯកអគ្គរាជទូត កូឡាឡាំពួរ

១០_ សាធារណរដ្ឋហ្វីលីពីន

– ស្ថានឯកអគ្គរាជទូត ម៉ានីល

១១_ ប្រទេសប្រ៊ុយណេ ដារុស្សាឡាម

– ស្ថានឯកអគ្គរាជទូតបណ្ដាសេរីបេក្កាវ៉ាន

១២_ ប្រទេសសេណេហ្គាល

– ស្ថានឯកអគ្គរាជទូត ដាកា

១៣_ ប្រទេសមីយ៉ាន់ម៉ារ

– ស្ថានឯកអគ្គរាជទូត យ៉ង់ហ្គូន

១៤_ សាធារណរដ្ឋកូរ៉េ

– ស្ថានគណៈបេសកកម្មព្រះរាជាណាចក្រកម្ពុជា សេអ៊ូល

១៥_ ក្រុងហុងកុង

– ស្ថានកុងស៊ុល ហុងកុង

៣_ សាធារណរដ្ឋឆែក

– ស្ថានឯកអគ្គរាជទូត ប្រាហ្គ

៤_ សាធារណរដ្ឋប៊ុលហ្គារី

– ស្ថានឯកអគ្គរាជទូតសូហ្វីយ៉ា

៥_ សាធារណរដ្ឋហុងគ្រី

– ស្ថានឯកអគ្គរាជទូត ប៊ុយដាប៉េស

សរុបប្រចាំខែ ដោយយោងតាមការបែងចែកបណ្តាប្រទេសជាប្រភេទ ក-ខ-គ ដូចមានចែងក្នុងមាត្រា ២ ខាងក្រោមនេះ ÷

ល.រ	ឋានៈនិងមុខងារ	ប្រាក់បំណាច់ប្រចាំខែតាមប្រភេទ ជាដុល្លារអាមេរិក		
		ក	ខ	គ
១	– ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព	2 700 $	2.200 $	1.500 $
២	– អនុប្រធានស្ថានបេសកកម្មអចិន្ត្រៃយ៍ប្រចាំ អ.ស.ប (មានឋានៈជាឯកអគ្គរាជទូត)	2.500 $		
៣	– ភារធារីពេញសមត្ថភាព – អគ្គទីប្រឹក្សាស្ថានទូត ស្ថានតំណាងអចិន្ត្រៃយ៍	2.200 $	1.800 $	1.200 $
៤	– ទីប្រឹក្សាស្ថានទូត , ទីប្រឹក្សាស្ថានតំណាង អចិន្ត្រៃយ៍ –ទីប្រឹក្សាយោធា – ទីប្រឹក្សាបច្ចេកទេស (សេដ្ឋកិច្ច–ពាណិជ្ជកម្ម អប់រំវប្បធម៌ .....) – អគ្គកុងស៊ុល	1.900 $	1.600 $	1.100 $
៥	–លេខាធិការទី ១ ស្ថានទូតឬស្ថានតំណាង អចិន្ត្រៃយ៍ – អនុពន្ធយោធា – អនុពន្ធជំនាញបច្ចេកទេស (សេដ្ឋកិច្ច–ពាណិជ្ជកម្ម អប់រំវប្បធម៌ .....)	1.800 $	1.400 $	1.000 $
៦	–លេខាធិការទី ២ ស្ថានទូតឬស្ថានតំណាង អចិន្ត្រៃយ៍ – កុងស៊ុល – អនុពន្ធយោធារង	1.700 $	1.300 $	900 $
៧	–លេខាធិការទី ៣ ស្ថានទូតឬស្ថានតំណាង អចិន្ត្រៃយ៍ – អនុកុងស៊ុល	1.600 $	1.200 $	800 $
	– អនុពន្ធស្ថានទូត ឬ ស្ថានតំណាងអចិន្ត្រៃយ៍	1.500 $	1.100 $	750 $
	–បុគ្គលិករដ្ឋបាល និង បច្ចេកទេស	1.200 $	1.000 $	600 $
១០	– បុគ្គលិកសេវា	1.000 $	800 $	500 $

មាត្រា ៣ . មន្ត្រីរាជការការទូតដែលត្រូវតែងតាំងជាភារធារីនៃស្ថានឯកអគ្គរាជទូត ឬ ស្ថានបេសកកម្មអចិន្ត្រៃយ៍ ត្រូវបានទទួលប្រាក់ឧបត្ថម្ភបន្ថែមស្មើនឹង ១០%នៃប្រាក់បំណាច់សរុបប្រចាំខែដើម របស់ខ្លួន ដោយយោងតាមការបែងចែកបណ្តាប្រទេសជាប្រភេទ ក-ខ-គ ដូចមានចែងក្នុងមាត្រាខាងលើ ។

មាត្រា ៤ . បន្ថែមលើប្រាក់បំណាច់សរុបប្រចាំខែ ដូចបាននិទ្ទេសក្នុងមាត្រា ១ មន្ត្រីទាំងអស់នោះត្រូវមានសិទ្ធិទទួលប្រាក់ឧបត្ថម្ភពីរដ្ឋសំរាប់ ÷

ជួយរ៉ាប់រងឈ្នួលផ្ទះនៅបរទេស ដូចមានកំណត់ក្នុងតារាងខាងក្រោមនេះ ដោយយោងតាម ប្រភេទប្រទេស ក-ខ-គ :

ល.រ	ឋានៈនិងមុខងារ	ប្រាក់ឧបត្ថម្ភ ជាដុល្លារអាមេរិក		
		ក	ខ	គ
១	ចាប់ពីថ្នាក់អនុប្រធានស្ថានបេសកកម្មអចិន្ត្រៃយ៍ប្រចាំ អ.ស.ប ទៅដល់ថ្នាក់លេខាធិការទី ១ និង ឋានៈប្រហាក់ប្រហែល (យោងតាមតារាងមាត្រាទី ១ ខាងលើ)	1.000,00 $	800,00 $	600,00 $
២	ចាប់ពីថ្នាក់លេខាធិការទី ២ ទៅដល់ថ្នាក់អនុពន្ធស្ថានទូត និង ឋានៈប្រហាក់ប្រហែល (យោងតាមតារាងមាត្រាទី ១ ខាងលើ)	900,00 $	700,00$	500,00$
៣	បុគ្គលិករដ្ឋបាល និងបច្ចេកទេស (យោងតាមតារាងមាត្រាទី ១ ខាងលើ)	800,00 $	600,00 $	400,00 $

ប្រាក់ឧបត្ថម្ភឈ្នួលផ្ទះ ត្រូវផ្តល់ជូនមន្ត្រីគ្រប់រូបដែលឥតមានស្នាក់នៅក្នុងអាគាររបស់រដ្ឋចាប់តាំងពីថ្នាក់ បុគ្គលិកមន្ត្រីរដ្ឋបាល និងបច្ចេកទេសឡើងទៅ ។

បុគ្គលិកសេវាត្រូវស្នាក់នៅជាមួយអាគារប្រធានស្ថានទូត ស្ថានកុងស៊ុល ឬ ស្ថានបេសកកម្មអចិន្ត្រៃយ៍ ហើយឥតមានសិទ្ធិ និងទទួលនូវប្រាក់ឧបត្ថម្ភឈ្នួលផ្ទះនោះឡើយ ។

មាត្រា៥ . រដ្ឋផ្តល់ជូនចំពោះមន្ត្រីរាជការទាំងអស់នូវប្រាក់ឧបត្ថម្ភធានារ៉ាប់រងនិរភ័យសង្គម (assurance maladie ou securite sociale) ក្នុងករណីចាំបាច់ ។

មាត្រា៦ . ឯកអគ្គរាជទូត មន្ត្រីការទូត មន្ត្រីកុងស៊ុល មន្ត្រីជំនាញ មន្ត្រីយោធា មន្ត្រីបច្ចេក រដ្ឋកាលបច្ចេកទេសត្រូវ[illegible] រ៉ាប់រងសោហ៊ុយយន្តហោះ ដើម្បីធ្វើដំណើរ ទៅកាន់តំណែងតំបូង[illegible] និងត្រឡប់មកប្រទេសវិញពេលចប់អាណត្តិ ។

ក្នុងការធ្វើដំណើរនេះឯកអគ្គរាជទូតត្រូវបានប្រាក់ឧបត្ថម្ភសំរាប់រ៉ាប់រងថ្លៃ ដឹកឥវ៉ាន់ដែលលើសទម្ងន់[illegible] ចំនួនសរុបមិនលើសពី ៥០ គ.ក្រ

– ចំពោះមន្ត្រីថ្នាក់ដទៃទៀត ប្រាក់ឧបត្ថម្ភសំរាប់រ៉ាប់រងថ្លៃដឹកឥវ៉ាន់លើស ទំងន់នេះ ត្រូវបានត្រឹមតែចំនួនសរុបមិនលើសពី ៣០ គីឡូក្រាមទេ ។

មាត្រា ៧. ឯកអគ្គរាជទូត ត្រូវបានអនុញ្ញាតអោយយកប្រពន្ធ ឬប្តីព្រមទាំងកូនក្នុងបន្ទុក (មានអាយុមិនលើសពី ១៨ ឆ្នាំ ឬ ២៥ឆ្នាំ បើមានវិញ្ញាបនប័ត្រសកលវិទ្យាល័យ) បានទៅតាមដោយរដ្ឋជួយឧបត្ថម្ភរ៉ាប់រងយន្តហោះ ចំពោះគ្រួសារទាំងមូល ពេលធ្វើដំណើរទៅកាន់ តំណែងតំបូងនៅបរទេស និងត្រឡប់មកប្រទេសវិញពេល ចប់អាណត្តិ ។

មាត្រា ៨ : ប្រាក់ឧបត្ថម្ភ និង ប្រាក់បំណាច់ផ្សេង ។ ចាប់អនុវត្តន៍ពីថ្ងៃទី ០១ តុលា ១៩៩៦ ទៅ ។

មាត្រា ៩ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា១០ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ មុខងារសាធារណៈគ្រប់ប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តន៍ អនុក្រឹត្យនេះ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៩៧ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែល ប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយសិរីវឌ្ឍ ស្ថាបនាជាតិ ជូនលោក **ឈុម ម៉េង** និងលោកស្រី **លី ស៊ីមសៀង** បានបរិច្ចាគថវិកា ចំនួន ១.៥០០$US សំរាប់ជួយសាងសង់សាលាបាលីនៅក្នុងវត្តព្រះវិហារសំណរ ស្រុកពញាឮ ខេត្តកណ្តាល ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាល ខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

ភ្នំពេញ, ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៩៨ អនក្រ.គត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

រាជរដ្ឋាភិបាល

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

–បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

–បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

–តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិ ជូនចំពោះសប្បុរសជន ដែលបានបរិច្ចាគថវិកាចូលរួមជួយស្ថាបនាសួនច្បារសម្តេច **ជា ស៊ីម** ស្ថិតនៅទល់មុខសណ្ឋាគារកាំបូឌីយ៉ាណាដូចមានរាយនាម ខាងក្រោមនេះ ÷

១–សណ្ឋាគារស្វ៊ីតែលកាំបូឌីយ៉ាណា	ឧបត្ថម្ភទឹកប្រាក់	៤០.០០០$US
២–លោកឧកញ៉ា គុក អាន	ឧបត្ថម្ភទឹកប្រាក់	៣០.០០០$US
៣–ក្រុមហ៊ុនភាពពីម៉ិច និងហ្ស៊ីបភីង	ឧបត្ថម្ភទឹកប្រាក់	២០.០០០$US
៤–**China Palace**	ឧបត្ថម្ភទឹកប្រាក់	២០.០០០$US
៥–ក្រុមហ៊ុន វឌ្ឍនៈ	ឧបត្ថម្ភទឹកប្រាក់	១០.០០០$US
៦–លោកឧកញ៉ា គីម ហាប់	ឧបត្ថម្ភទឹកប្រាក់	១០.០០០$US

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ត្រូវអនុវត្តតាមអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៩៩ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាសស្ថាបនាជាតិ ជូនឯកឧត្តម **អ៊ុំស្វាងឈ ខ្វស្ថាន** អនុរដ្ឋលេខាធិការ ក្រសួងធម្មការនិងសាសនា ដែលបានផ្តល់វិភាគទានជាទឹកប្រាក់ចំនួន

៥០.០០០$US សំរាប់ជួយជួសជុល និងសាងសង់អាគារសិក្សា ព្រះវិហារ ទីចតាម ខេត្តនានានៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋលេខាធិការ ក្រសួងធម្មការនិងសាសនា ត្រូវអនុវត្តតាមអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខានិងត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខានិងត្រា
ហ៊ុន សែន

* * *

ភ្នំពេញ, ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ២០០ អនក្រ.តត
ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិ ចំនួន ០៧គ្រឿងជូនអង្គការ REDD BARNA ដែលបានជួយកសាងសាលារៀនចំនួន ០៧កន្លែង នៅក្នុងរាជធានីភ្នំពេញដូចមានខាងក្រោមនេះ ÷

១_អាគារ ០១ ខ្នងមាន ០៥ បន្ទប់ នៅសាលាបឋមសិក្សាបឹងសាឡាង

អស់ទឹកប្រាក់_ ២៥.០០០ដុល្លារអាមេរិក

២_ អាគារ ០១ ខ្នងមាន ០៥ បន្ទប់ នៅសាលាបឋមសិក្សា ទួលគោក

អស់ទឹកប្រាក់_ ២៥.០០០ដុល្លារអាមេរិក

៣_អាគារ ០១ ខ្នងមាន ០៥បន្ទប់ នៅសាលាបឋមសិក្សាបឹងឈូកប្រជុំវង្ស

អស់ទឹកប្រាក់_ ២៥.០០០ដុល្លារអាមេរិក

៤_ អាគារ ០១ ខ្នងមាន ០៥ បន្ទប់ នៅសាលាបឋមសិក្សា ទួលសង្កែ

អស់ទឹកប្រាក់_ ២៥.០០០ដុល្លារអាមេរិក

៥_ អាគារ ០១ ខ្នងមាន ០៥ បន្ទប់ នៅសាលាបឋមសិក្សា ឫស្សីកែវ

អស់ទឹកប្រាក់_ ២៥.០០០ដុល្លារអាមេរិក

៦_អាគារ ០១ ខ្នងមាន ១០ បន្ទប់ នៅសាលាបឋមសិក្សា សន្ធរម៉ុក

អស់ទឹកប្រាក់_ ៩០.០០០ដុល្លារអាមេរិក

៧_អាគារ ០១ ខ្នងមាន ០៣ បន្ទប់ នៅសាលាបឋមសិក្សា ចំរើនជាតិ

អស់ទឹកប្រាក់_ ១៥.០០០ដុល្លារអាមេរិក

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ២០១ អនក្រ.តត

ស្ដីពីការជូនមេដាយស្ថាបនាជាតិ

* * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ អស្សឫទ្ធិ សហមេត្រី ជូនលោកវរៈសេនីយត្រី **DE GOUVELLO ERWAN** ទីប្រឹក្សាប្រធានក្រុមបេសកកម្មយោធាបារាំង ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្ត តាមអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ដលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្ដម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ២០២ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ សេនា សហមេត្រី ជូនលោកវរៈសេនីយត្រី JAN WANDER- STEIN ទីប្រឹក្សាយោធា តំណាងអគ្គលេខាធិការអង្គការ សហប្រជាជាតិប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដែលបានមកបំពេញបេសកកម្ម នៅកម្ពុជា ទទួលបានលទ្ធផលល្អគួរជាទីពេញ ចិត្ត ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តតាមអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

២—សេចក្ដីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

សេចក្ដីសំរេចលេខ ៤៥ សសរ.

ស្ដីពីការបង្កើតគណៈកម្មការពិនិត្យលក្ខណសម្បត្តិ វរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណូមពរចាំបាច់ក្នុងការលើកទឹកចិត្ត ចំពោះវរជនដែលមានគុណបំណាច់ដ៏ធំធេងចំពោះជាតិមាតុភូមិ

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការមួយ មានឈ្មោះថា គណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវ ជូនគ្រឿងឥស្សរិយយស ។

ប្រការ ២ : សមាសភាពគណៈកម្មការនេះរួមមាន ÷

១_ឯកឧត្ដម អគ្គលេខាធិការរាជរដ្ឋាភិបាល ប្រធាន

២_ឯកឧត្ដមសហរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ អនុប្រធាន

៣_ឯកឧត្តមសហរដ្ឋលេខាធិការ ក្រសួងការពារជាតិ អនុប្រធាន
៤_ឯកឧត្តមរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សមាជិក
៥_លោកប្រធាននាយកដ្ឋានឥស្សរិយយស លេខា

ប្រការ ៣ : គណៈកម្មការនេះមានភារកិច្ចពិនិត្យលក្ខណសម្បត្តិវរជន នៃព្រះរាជាណាចក្រកម្ពុជា ដែលមានព្រះរាជគុណបំណាច់ និងគុណបំណាច់ដ៏ខ្ពង់ខ្ពស់ក្នុងការដឹកនាំពុះពារ ប្រយុទ្ធទាំងលើសមរភូមិក៏ដូចជាលើវិស័យនយោបាយការទូត និងសេដ្ឋកិច្ច ដើម្បីបុព្វហេតុការពារបូរណភាពទឹកដី ឯករាជ្យ សន្តិភាព ប្រជាធិបតេយ្យ សាមគ្គីភាពជាតិព្រមទាំងការងារស្តារ និង អភិវឌ្ឍន៍ប្រទេសជាតិ រួចស្រង់បញ្ជីឈ្មោះដាក់ជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យសំរេចផ្តល់ គ្រឿងឥស្សរិយយស ទៅតាមប្រភេទ និងទៅតាមទំហំស្នាដៃ ដែលបានបំរើប្រទេសជាតិកន្លងមក ។

ប្រការ ៤ : សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និងសមាសភាពគណៈកម្មការដូចមានចែងក្នុងប្រការ ២ ត្រូវ អនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ៤៦ សសរ.

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
_បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
_បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤·

–តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

សម្រេច

ប្រការ ១ : ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីធ្វើការវាយតំលៃលើការប៉ះពាល់ដល់សំណង់ ផ្ទះសម្បែង និងដីធ្លីប្រជារាស្ត្រ ក្នុងគំរោងសាងសង់ស្ពានឆ្លងកាត់ទន្លេមេគង្គក្នុងខេត្តកំពង់ចាម ។

ប្រការ ២ : គណៈកម្មការអន្តរក្រសួង មានសមាសភាពដូចខាងក្រោម ÷

១–តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធាន

២–តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៣–តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន សមាជិក

៤–តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ សមាជិក

៥–ឯកឧត្តមអភិបាលខេត្តនិងឯកឧត្តមអភិបាលខេត្តរងទី១ខេត្តកំពង់ចាម សមាជិក

ប្រការ ៣ : គណៈកម្មការអន្តរក្រសួង មានភារកិច្ចចុះទៅពិនិត្យដល់ទីកន្លែង ធ្វើស្ថិតិពីការប៉ះពាល់ដល់សំណង់ ផ្ទះសម្បែង និងដីធ្លីរបស់ប្រជារាស្ត្រ រួចធ្វើការវាយតំលៃអោយបានត្រឹមត្រូវតាមការជាក់ស្តែង ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យនិងសំរេចនូវថវិកាមួយចំនួនសំរាប់សងដល់ប្រជារាស្ត្រខាងលើវិញ ។

ប្រការ ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ឯកឧត្តមអភិបាលខេត្តកំពង់ចាម និងបណ្តាស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

III- ការងារបណ្ដាក្រសួង

១— ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ ៦៥០ ឧក.ប្រក ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក យ៉ីវ ពៅ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ១៤៥៤៦៩ ក.ឆ ចុះថ្ងៃទី ០២ - ៧- ៩២ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ តាកុយ ឃុំ ពានី ស្រុក កំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **យ៉ីវ** ពៅ ត្រូវចាប់ផ្ដើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំង ដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិច បំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិ ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូត វិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៦៥១ ឧក.ប្រក ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **កែវ សៀង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ២២១៧៤៩ ភ.ព ចុះថ្ងៃទី ០៨ - ៤- ៨៩ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៨៩ អ៊ីអូ ផ្លូវលេខ ១៥៩ សង្កាត់ ផ្សារកណ្ដាលទី ២ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ បើកដំណើរ ការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៧០ សេះ នៅក្នុងទីតាំង ភូមិ ការអត ឃុំ ពានី ស្រុក កំពង់ត្រឡាច ខេត្ត កំពង់ឆ្នាំង ។

ប្រការ ២ : អ្នកស្រី **កែវ សឿន** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូច បានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិ ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូត វិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៦៥២ ឧក.ប្រក ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ពុយ ស៊ីកន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណលេខ ៣០៣៩៦២ ភ.ព ចុះថ្ងៃទី ១៤ - ៣- ៩១ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៥ ភូមិ លូ សង្កាត់ ស្វាយប៉ាក ខ័ណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ បន្ត ដំណើរការឡផលិតឥដ្ឋ-ក្បឿង នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិ ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូត វិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៦៥៣ ឧក.ប្រក ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **អ៊ឹង ម៉ាក់សេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជាកាន់អត្ត សញ្ញាណប័ណ្ណ លេខ ២៥៣៦៧១ ភ.ព ចុះថ្ងៃទី ២៧ -៧- ៩៣ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៣៦ ហ្សិតអឺ១ ផ្លូវលេខ ១៩ សង្កាត់ ផ្សារចាស់ ខ័ណ្ឌ ដូនពេញ រាជធានីភ្នំពេញ បន្តដំណើរការ ឡផលិតឥដ្ឋ-ក្បឿង នៅក្នុងទីតាំង ភូមិ ៤ សង្កាត់ ច្រាំងចំរេះទី ១ ខ័ណ្ឌ ឫស្សីកែវរាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណង ឡើយ ។

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

* * *

ប្រកាសលេខ ៦៥៤ ឧក.ប្រក ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ថុង ឈីងលី** ជនជាតិចិន សញ្ជាតិចិន កាន់អត្តសញ្ញាណប័ណ្ណលេខ P ១៦៨៦៦១៣ ក.ព ចុះថ្ងៃទី ១៧ - ៥- ៩៦ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៩៨ ផ្លូវលេខ ១៦០ សង្កាត់ ទឹកល្អក់ទី ២ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ បើកដំណើរការសិប្បកម្មផលិតការ៉េម និង ទឹកផ្លែឈើ នៅក្នុងទីតាំងដូចអាស្រ័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ថុង ឈីងលី** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផល ការ៉េម (ក្លិនផ្លែឈើ) សញ្ញា « ផែនទី SN- រូបប៊ិនធ្វីន» ការ៉េម (ទឹកផ្លែឈើទឹកដោះគោ) សញ្ញា «ផែនដីSN- រូបកូនក្មេងអង្គុយ » និងការ៉េម (កាកាវទឹកដោះគោ)សញ្ញា «ផែនដីSN-រូបកូនក្មេងរត់ » ស្របតាមគំរូសញ្ញាសំគាល់ ដែលបានដំកល់ទុក នៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

អ៊ិត ប្រាំង

២– ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៣០៧/៩៦ ពម.ប្រក

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី ៤១

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា នៃ ព្រះរាជាណាចក្រកម្ពុជា

– បានឃើញច្បាប់ ស្តីពីរបបសាពត៌មាន នៃ ព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ តាមព្រះរាជក្រមលេខ ន.សរក.ម ០៨៩៥-០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥

– បានឃើញសំណើ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ស្តីពីការសុំប្តូរឈ្មោះចាងហ្វាងពីលោក **ហេង គីម** មកលោក **សម សារិ** វិញ និង សុំប្តូរឈ្មោះសារពត៌មាន «សង្គមខ្មែរ» មកសារពត៌មាន «សេរីភាពខ្មែរ» ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតអោយផ្ទេរសិទ្ធិចាងហ្វាងនិងឈ្មោះសារពត៌មាន « សង្គមខ្មែរ » មក «សេរីភាពខ្មែរ» វិញដោយមានលោក សម សារិ ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការលេខ ៤៤ អឺអូ ផ្លូវ ៣៨៦ សង្កាត់បឹងកេងកង ៣ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរនូវចំណុចណាមួយក្នុងអត្តសញ្ញាណនៃសារពត៌មានរបស់ខ្លួនត្រូវជូនដំណឹងជាមុន ៥ ថ្ងៃមកក្រសួងពត៌មាន ដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

ប្រការ ២ : រាល់ដំណើការបោះពុម្ពចែកផ្សាយ ត្រូវគោរពតាមគោលការណ៍ក្រមសីលធមិអ្នកសាពត៌មាន និង ឈរលើស្មារតីទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។

ខ្លឹមសារអត្ថបទត្រូវអនុវត្តអោយបានសមស្របតាមទំនៀមទំលាប់ប្រពៃណី ល្អ និងច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា រួចស្នើប្រគល់សារពត៌មានចំនួន ៦ច្បាប់ រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសអំពីសេចក្តីដូចមានចែងក្នុងប្រការ១ និង ប្រការ២ ខាងលើ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាននៃក្រសួងពត៌មាន និង ចាងហ្វាងសារពត៌មាន «សេរីភាពខ្មែរ» ត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះ មានប្រសិទ្ធិភាពរយៈពេល ២ឆ្នាំ និង ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

៣— ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៩៥១ អយក.ប្រ.ក

ស្តីពីការអនុញ្ញាតអោយបើកសាលាមត្តេយ្យ

ឯកជន ម៉ុន្តេសសូរី

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅ

ក្រុងកម្ពុជាធិបតីចុះថ្ងៃទី ០១/១១/១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល

–បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជា ធិបតី លេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦/៧/៩៦ ស្តីពីការប្រព័ន្ធអប់រំចំនេះទូទៅ ១២ ឆ្នាំ

–បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០/៧/៩៤

–បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ១៥/៦/៩២ ស្តីពីការបើកសាលារៀនចំនេះទូទៅឯកជន

–បានឃើញលិខិតលេខ ៥១៨ អយក.ចទម ចុះថ្ងៃទី ០៥/៤/៩៤ របស់ក្រសួងអប់រំយុវជន និង កីឡា

–បានពិនិត្យពាក្យស្នើសុំរបស់អ្នកស្រី **សូសែត ឡោ** ចុះថ្ងៃទី ១៣/៨/៩៤ ដោយមានចំណារ ឯកភាពរបស់មន្ទីរអប់រំយុវជន និង កីឡា រាជធានីភ្នំពេញ ចុះថ្ងៃទី ០៣/៥/៩៥ និងចំណារឯកភាពរបស់ឯកឧត្តម អភិបាលនៃប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានី ភ្នំពេញ ចុះថ្ងៃទី ០៦/១/៩៦

–តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និង មតេយ្យសិក្សា

សម្រេច

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **សូសែត ឡោ** បើកសាលាមត្តេយ្យឯកជន ម៉ុនេ្តសស្សូរី ដែលមានទីតាំងនៅលើដីឡូត៍ ផ្ទះលេខ ២១៩ ផ្លូវ ៥១ សង្កាត់បឹងកេងកង១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីឆ្នាំសិក្សា ១៩៩៦- ៩៧ នេះតទៅ ។

ប្រការ ២ : សាសាមត្តេយ្យឯកជន ម៉ុនេ្តសស្សូរី ត្រូវនៅក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំយុវជន និង កីឡា រាជធានីភ្នំពេញ និងត្រូវអនុវត្តកម្មវិធីសិក្សាតាមកំរិតថ្នាក់មត្តេយ្យ តាមការអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

ប្រការ ៣ : អ្នកស្រី **សូសែត ឡោ** ត្រូវដឹកនាំ គ្រប់គ្រង ចាត់តាំងគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន ដែលមានសមត្ថភាពគុរុកោសល្យសមស្រប ព្រមទាំងអនុវត្តអោយបានត្រឹមត្រូវតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និង កីឡា ។ ។

ប្រការ ៤ : លោកប្រធានមន្ទីរ នៃក្រសួងអប់រំ យុវជន និង កីឡា លោកប្រធាននាយកដ្ឋានចំនេះទូទៅ និង មតេយ្យសិក្សា លោកប្រធាននាយកដ្ឋានចាត់តាំងលោកប្រធាន

នាយកដ្ឋានផែនការ_ហិរញ្ញកិច្ច លោកប្រធាន មន្ទីរអប់រំយុវជន និង កីឡា រាជធានីភ្នំពេញ លោកប្រធានការិយាល័យអប់រំ យុវជន និង កីឡា ខ័ណ្ឌ ចំការមន នាយកសាលាមត្តេយ្យឯកជន ម៉ុន្តេសស្សូរី និង អ្នកស្រី **សូសែត ឡោ** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ហត្ថលេខា និង ត្រា

គា សាហាន

* * *

៤_ទីស្តីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រកាស លេខ : ៧២ ប្រក.បឈ.៩៦

ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ នស.រកម.០១៩៦.០៤
- បានឃើញច្បាប់ ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋ កម្ពុជាដែលបានប្រកាសអោយប្រើ ដោយក្រឹត្យលេខ ០៦.ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣
- បានឃើញលិខិតលេខ ២៨២.៩៦ របស់មហាអយ្យការអមសាលាឧទ្ធរណ៍ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៦

សម្រេច

មាត្រា ១ : មន្ត្រីរាជការដែលមានឈ្មោះដូចខាងក្រោមត្រូវបានផ្ទេរទៅបំរើការងារនៅមហាអយ្យការ អមសាលាឧទ្ធរណ៍ ÷

ល.រ	គោត្តនាម និង នាម	មុខងារបច្ចុប្បន្ន	អង្គភាព
១	លោក សាយ សុខហៀង	ក្រឡាបញ្ជី	តុលាការខេត្តកោះកុង
២	លោកស្រី ទី គឹមស្រ៊ាន	–	តុលាការក្រុងភ្នំពេញ
៣	លោកស្រី អ៊ិត ដាលី	–	–
៤	លោកស្រី ជា បញ្ញា	–	–
៥	លោក នាង សារឿន	–	ក្រសួងយុត្តិធម៌
៦	លោក សុខ ភូមី	បុគ្គលិក	–
៧	លោក សែ យូរ៉ាន់	–	–
៨	លោក នៅ សូបិន	–	–

មាត្រា ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗត្រូវបានបើកនៅអង្គភាពថ្មី បន្ទាប់ពីបានផ្តាច់ចេញពីអង្គភាពដើម ។

មាត្រា ៣ : សាលាឧទ្ធរណ៍ មហាអយ្យការអមសាលាឧទ្ធរណ៍ តុលាការក្រុងភ្នំពេញ នាយកដ្ឋានបុគ្គលិក និង បណ្តុះបណ្តាល មន្ទីរ «ការិយាល័យគណនេយ្យ» ក្រសួងយុត្តិធម៌ និងសាមីខ្លួន ត្រូវអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

ចែម ស្ងួន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៧៣ បល.៩៦

ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជាដែល បានប្រកាសអោយប្រើ ដោយក្រឹត្យលេខ ០៦.ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣
- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌ ដែលប្រកាសអោយប្រើតាមព្រះរាជក្រម លេខ នស.រកម.០១.៩៦.០៤

សំរេច

មាត្រា ១ : ផ្ទេរក្រឡាបញ្ជីរបស់ក្រសួងយុត្តិធម៌ និង សាលាឧទ្ធរណ៍ អោយទៅបំរើការងារនៅតុលាការរាជធានីភ្នំពេញ ដែលមានឈ្មោះដូចខាងក្រោម ជំនួសក្រឡាបញ្ជីដែលបានមកសាលាឧទ្ធរណ៍ ÷

១- កញ្ញា ជា ស្រីមុំ ជំនួសលោកស្រី ទី គីមស្រ៊ាន

២- លោក រស់ អួន ជំនួសលោកស្រី អ៊ិត ដាលី

៣- លោក ទូរ ជារ៉ាត ជំនួសលោកស្រី ជា បញ្ញា

មាត្រា ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗត្រូវបានបើកនៅអង្គភាពថ្មី បន្ទាប់ពីបានផ្តាច់ចេញពីអង្គភាពចាស់ ។

មាត្រា ៣ : នាយកដ្ឋាន បុគ្គលិក និង បណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌ មន្ទីរ នាយកដ្ឋានព្រហ្មទណ្ឌ និង រដ្ឋប្បវេណី សាលាឧទ្ធរណ៍ និង សាមីខ្លួន ត្រូវអនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

ចែម ស្គួន

រាជធានីភ្នំពេញ , ថ្ងៃទី ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៧៥ ប្រក.បឈ.៩៦

ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌ ដែលប្រកាសអោយប្រើតាម ព្រះរាជក្រមលេខ នស.រកម.០១៩៦.០៤
- បានឃើញច្បាប់ ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋ កម្ពុជាដែល បានប្រកាសអោយប្រើ ដោយក្រឹត្យលេខ ០៦.ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣
- បានឃើញពាក្យសុំផ្ទេររបស់លោក **សាយ ខៃ** ចុះថ្ងៃទី ២៨ តុលា ១៩៩៦

សំរេច

មាត្រា ១ : លោក **សាយ ខៃ** ជាក្រឡាបញ្ជីអយ្យការអមតុលាការខេត្តបាត់ដំបង ត្រូវបានផ្ទេរ អោយមកបំរើការងារនៅតុលាការខេត្តកណ្តាល ។

មាត្រា ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ ត្រូវបានបើកនៅតុលាការខេត្តកណ្តាល បន្ទាប់ពីបានផ្តាច់ចេញពីបញ្ជីបើកប្រាក់របស់តុលាការខេត្តបាត់ដំបង ។

មាត្រា ៣ : តុលាការខេត្តកណ្តាល តុលាការខេត្តបាត់ដំបង នាយកដ្ឋានបុគ្គលិក និង បណ្តុះបណ្តាល នៃក្រសួងយុត្តិធម៌ និង សាម៉ីខ្លួន ត្រូវអនុវត្តប្រកាសនេះអោយ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

ចែម ស្នួន

* * *

៥— ទីស្តីការក្រសួងធម្មការ និង សាសនា

សេចក្តីសំរេច

ភ្នំពេញ , ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ២៣១/៩៦ ក.ធ.ស

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ ន.ស.រ.ក.ម - ០១៩៦ - ១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃ ព្រះរាជាណាចក្រកម្ពុជា លេខ ០៦ ន.ស ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ២២ អ.ន.ក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ដែលស្តីពី ការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រសួងធម្មការ និង សាសនា
- បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំចិន សាសនាម៉ូលីក ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ១៩៩០ ព្រមទាំងមានចំណារបញ្ជូន របស់អភិបាលខេត្តក្រចេះ លេខ ៧៨៥ .ចណ.ក្រច ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតច្បាប់ជាគោលការណ៍អោយបើក សាខាស្នាក់ការថ្វាយបង្គំ នៃ សាសនាម៉ូលីកមួយកន្លែង ដែលមានទីតាំងស្ថិតនៅ ផ្ទះលេខ ២០៥ ផ្លូវលេខ ០៣ នៅទីរួមខេត្តក្រចេះ ខេត្តក្រចេះ ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំនេះ គោរពបូជាតាម សាសនាម៉ឺលីក នឹង ត្រូវអនុញ្ញាត អោយផ្សព្វផ្សាយនូវលទ្ធិសាសនា និង រាល់ឯកសារផ្សេងៗ ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ៣ : បរិស័ទទាំងអស់ នៃ សាសនាម៉ឺលីក ត្រូវគោរពអោយបានម៉ឺងម៉ាត់ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំសាសនា នៃស្នាក់ការនេះ ត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អ ជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាង ជំនឿសាសនា និង សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ផ្ទុយពី សេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា - មន្ទីរធម្មការ និង សាសនា ខេត្តក្រចេះ និង មន្ត្រីរាជការគ្រប់ លំដាប់ថ្នាក់ ដែលមានភារកិច្ចពាក់ព័ន្ធត្រូវសហការអនុវត្ត សេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និង ត្រា

ហឿន វណ្ណរ័ត្ន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

សេចក្តីសំរេច លេខ : ២៣៣/៩៦ ក.ធ.ស

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ ន.ស.រ.ក.ម - ០១៩៦ - ១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃ ព្រះរាជាណាចក្រកម្ពុជា លេខ ០៦ ន.ស ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ២២ អ.ន.ក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ដែលស្តីពី ការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា
- បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តនិកាយប្រូតេស្តង់ឈ្មោះ « ព្រះវិហាររផ្លូវ ចំរូត » ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៦ ព្រមទាំងមានចំណារបញ្ជូនរបស់ អភិបាលប្រចាំរាជធានី ភ្នំពេញ លេខ ៣៣១៧ ធ.ត.ស. ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១: អនុញ្ញាតច្បាប់ជាគោលការណ៍អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តនិកាយប្រូតេស្តង់ឈ្មោះ « ព្រះវិហាររផ្លូវចំរូត » មួយកន្លែង ដែលមានទីតាំងស្ថិតនៅផ្ទះលេខ ២២៧ ផ្លូវលេខ ១៥០ សង្កាត់ ទឹកល្អក់ទី២ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្ទនិកាយប្រូតេស្តង់ឈ្មោះ « ព្រះវិហាររផ្លូវចំរូត » គោរពបូជាតាម សាសនាម៉ុលីក នឹង ត្រូវអនុញ្ញាត អោយផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់សាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនា សុទ្ធសាធ ។

ប្រការ៣ : បរិស័ទ នៃ សាសនាគ្រីស្ទឈ្មោះព្រះវិហាររផ្លូវចំរូត ត្រូវគោរពអោយ បានម៉ឺងម៉ាត់តាមច្បាប់នៃ ព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនា ។ អ្នកដឹកនាំ នៃស្នាក់ការនេះត្រូវមានសាមគ្គីភាព និងទំនាក់ទំនងអោយបានល្អ ជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិន ធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាង ជំនឿសាសនា និង សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ផ្ទុយពី សេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា - មន្ទីរធម្មការ និង សាសនា រាជធានីភ្នំពេញ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានភារកិច្ចពាក់ព័ន្ធត្រូវសហការអនុវត្ត សេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ។

ប្រការ ៦ : សេចក្ដីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និង ត្រា

សេឡឹង ឧណ្ណរ័ត្ន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

សេចក្ដីសំរេច លេខ : ២៣៤/៩៦ ក.ធ.ស

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្ដីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ ធ.ស.រ.ក.ម - ០១៩៦ - ១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃ ព្រះរាជាណាចក្រកម្ពុជា លេខ ០៦ ធ.ស ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ២២ អ.ធ.ក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ដែលស្ដីពី ការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា
- បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ដឈ្មោះ « ក្រុមជំនុំគ្រិស្ដបរិស័ទខ្មែរ ចាប់ទីស្ទ » ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៩៦ ព្រមទាំងមានចំណារបញ្ជូនរបស់អភិបាល ខេត្តព្រៃវែង លេខ ៤៣/៩៥ រប. ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតច្បាប់ជាគោលការណ៍អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ដនិកាយប្រូតេស្តង់ឈ្មោះ « ក្រុមជំនុំគ្រិស្ដបរិស័ទខ្មែរចាប់ទីស្ទ » មួយកន្លែង ដែលមានទីតាំងស្ថិតនៅ ភូមិប្រស្រែមុខ ឃុំ កញ្ច្រៀច ស្រុក កញ្ច្រៀច ខេត្តព្រៃវែង ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្ទឈ្មោះ «ក្រុមជំនុំគ្រីស្ទបរិស័ទខ្មែរ បាប់ទីស្ទ » ត្រូវអនុញ្ញាតអោយផ្សព្វផ្សាយនូវលទ្ធិសាសនា និង រាល់ឯកសារផ្សេងៗ ដែលមានលក្ខណៈជា សាសនាសុទ្ធសាធ ។

ប្រការ៣ : បរិស័គ្រីស្ទទាំងអស់នៃស្នាក់ការក្រុមជំនុំគ្រីស្ទបរិស័ទខ្មែរបាប់ទិស» ត្រូវគោរពអោយ បានម៉ឺងម៉ាត់តាមច្បាប់នៃ ព្រះរាជាណាចក្រកម្ពុជានិងរាល់ បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនា ។ អ្នកដឹកនាំសាសនា នៃស្នាក់ការនេះ ត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អ ជាមួយស្ថាប័ន ពាក់ព័ន្ធសន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿ សាសនា និង សណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ផ្ទុយពី សេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា - មន្ទីរធម្មការ និង សាសនា ខេត្តព្រៃវែង និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធត្រូវសហការអនុវត្ត សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និង ត្រា

ហៀង ឧណ្ណារិទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ២៣៥/៩៦ ក.ធ.ស

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាស

អោយប្រើ តាមព្រះរាជក្រមលេខ ន.ស.រ.ក.ម - ០១៩៦ - ១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

– បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃ ព្រះរាជាណាចក្រកម្ពុជា លេខ ០៦ ន.ស ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤

– បានឃើញអនុក្រឹត្យលេខ ២២ អ.ន.ក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ដែលស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា

– បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តឈ្មោះ « ព្រះវិហារសាវ័កថ្មី » ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៦ ព្រមទាំងមានចំណារបញ្ជូនរបស់អភិបាលក្រុង ព្រះសីហនុ លេខ ៤៣២/៩៦ អក.កពន ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតច្បាប់ជាគោលការណ៍អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត ឈ្មោះ « ព្រះវិហារសាវ័កថ្មី » មួយកន្លែង ដែលមានទីតាំងស្ថិតនៅ ក្រុមទី ០៩ មណ្ឌល ០៣ សង្កាត់លេខ ០៤ ខ័ណ្ឌ មិត្តភាព ក្រុង ព្រះសីហនុ ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំនៃសាសនាគ្រីស្ទឈ្មោះ « ព្រះវិហារសាវ័កថ្មី» ត្រូវអនុញ្ញាតអោយផ្សព្វផ្សាយនូវលទ្ធិសាសនា និង រាល់ឯកសារផ្សេងៗ របស់សាសនាគ្រីស្ទ ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ៣ : បរិស័ទទាំងអស់ នៃ នៃសាសនាគ្រីស្ទឈ្មោះ «ព្រះវិហារសាវ័កថ្មី» ត្រូវគោរពអោយបានម៉ឺងម៉ាត់តាមច្បាប់នៃ ព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនាអ្នកដឹកនាំស្នាក់ការ នៃ សាសនាគ្រិស្ទឈ្មោះ « ព្រះវិហារសាវិកថ្មី » ត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធសន្យាជាដាច់ខាតមិនធ្វើអោយ ប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និង សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម។

ប្រការ ៤ : រាល់ការអនុវត្តន៍ផ្ទុយពី សេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា - មន្ទីរធម្មការ និង សាសនា ក្រុងព្រះសីហនុ និង មន្ត្រីរាជការគ្រប់ លំដាប់ថ្នាក់ ដែលមានភារកិច្ចពាក់ព័ន្ធត្រូវសហការអនុវត្ត សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និង ត្រា

ហៀង វណ្ណារ័ត្ន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ២៣៧/៩៦ ក.ធ.ស

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ ន.ស.រ.ក.ម - ០១៩៦ - ១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃ ព្រះរាជាណាចក្រកម្ពុជា លេខ ០៦ ន.ស ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ២២ អ.ន.ក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ដែលស្តីពី ការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា
- បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តឈ្មោះ « ព្រះវិហារសេវេនដេយ អាត់វេនទីស្ទ » ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៦ ព្រមទាំងមានចំណារបញ្ជូនរបស់ អភិបាលខេត្តបន្ទាយមានជ័យ លេខ ៥៤០ ខ.ប.ជ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតច្បាប់ជាគោលការណ៍អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត ឈ្មោះ « ព្រះវិហារសេវេនដេយអាត់វេនទីស្ត » មួយកន្លែង ដែលមាន ទីតាំង ស្ថិតនៅផ្ទះលេខ ៨៣៦ ភូមិអូរអំបិល ស្រុកសេរីសោភ័ណ ខេត្តបន្ទាយ មានជ័យ ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្តឈ្មោះ « ព្រះវិហារសេវេនដេយ អាត់វេនទីស្ត » ត្រូវអនុញ្ញាតអោយផ្សព្វផ្សាយនូវលទ្ធិសាសនា និង រាល់ឯកសារផ្សេងៗ ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ៣ : បរិស័ទគ្រីស្តទាំងអស់ នៃស្នាក់ការសាសនាគ្រីស្តឈ្មោះ«ព្រះវិហារសេវេនដេយអាត់វេនទីស្ត» ត្រូវគោរពអោយបានម៉ឺងម៉ាត់ តាមច្បាប់នៃ ព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនា អ្នកដឹកនាំស្នាក់ការត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អ ជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយ ប៉ះពាល់ដល់សិទ្ធិសេរីភាពខាង ជំនឿសាសនា និង សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម។

ប្រការ ៤ : រាល់ការអនុវត្តន៍ផ្ទុយពី សេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា - មន្ទីរធម្មការ និង សាសនា ខេត្តបន្ទាយមានជ័យ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានភារកិច្ចពាក់ព័ន្ធត្រូវសហការអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និង ត្រា

សឿន ចន្ទរ៉ាន់

បោះពុម្ពនៅរោងពុម្ព ទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ៨០០ ច្បាប់

តម្លៃ ១០៤០ រៀល